# របាយការណ៍ប្រចាំត្រីមាសទី២
# ឆ្នាំ ២០២៣

០១ មេសា - ៣០ មិថុនា ២០២៣

## អ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.



ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-០០០, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៤២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី២ ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ១.០២៥.៨៨៨.៧៣៣ | ៨៨៩.២៩៥.២៣២ | ៦០៨.១៥៩.៥៣០ |
| បំណុលសរុប | ៤៨៥.៤៦៦.១៧៣ | ៤៥១.៣៩២.៤៣៣ | ៣២២.២៤០.៨២០ |
| មូលធនក្រុមហ៊ុនសរុប | ៥៤០.៤២២.៥៦០ | ៤៣៧.៩០២.៧៩៩ | ២៨៥.៩១៨.៧១០ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី ២ ២០២៣ | ត្រីមាសទី ២ ២០២២ | ត្រីមាសទី ២ ២០២១ |
|---|---|---|---|
| ចំណូលសរុប | ៤៨៧.០៧០.៦១៥ | ៣២១.៧៧៩.៧១៨ | ៣១៥.០៣០.៧៥១ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ៤៩.២៩៩.៨២៩ | ៤១.៩០២.៨៨៥ | ៣២.១៣៨.៥៤៦ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ៤៣.៦០៣.៤៦៨ | ៣៤.៧២៣.៨០៦ | ២៧.៥៧៩.៣៤០ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ៥២.៩៥៤.៣៩៦ | ៣៦.៤៤១.៩៧៦ | ២៩.៣៤០.១៥៤ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី ២ ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| អនុបាតសាធនភាព | ០,៩ | ១,០ | ១,១ |
| អនុបាតចរន្ត (Current Ratio) | ២,០ | ២,០ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ០,៦ | ០,៧ | ១,០ |

| អនុបាតចំណេញភាព | ត្រីមាសទី ២ ២០២៣ | ត្រីមាសទី ២ ២០២២ | ត្រីមាសទី ២ ២០២១ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ៥,៥% | ៥,៧% | ៦,៩% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ១០,៨% | ១១,៤% | ១៣,៥% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៨,៣% | ១៩,១% | ១៤,៨% |
| គម្លាតចំណេញ (Profit Margin) | ១០,៩% | ១១,៣% | ៩,៣% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ៨,៤ | ២០,៩ | ១៥,៧ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12%
11%
10%
9%
8%
7%
6%
២.២០៣.២៥៣.៤៥៣
១១%
១.៦២៦.៥៤០.០២៤
១០%
១០%
១.១១៦.៧៣០.៦៩៣
២០២១
២០២២
ខែមករា-ខែមិថុនា ឆ្នាំ២០២៣
ប្រាក់ចំណូល
ចំណូលសុទ្ធ %

# សមាជិកក្រុមប្រឹក្សាភិបាល



លោក Wiedmann Christian | លោក ឯន សាំង | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

លោក ឯន សាំង

អភិបាលប្រតិបត្តិ

លោក Tom Whitcraft

អភិបាលមិនប្រតិបត្តិ

លោក Wiedmann Christian

អភិបាលមិនប្រតិបត្តិ

លោក Ith Vichit

អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ រិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានកែសម្រួលអត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) ឆ្នាំ ២០២៣ របស់កម្ពុជានៅដើមខែកក្កដាមកត្រឹម ៥,៥% ធៀបនឹង ៥,៦% មុននេះ។ ធនាគារជាតិនៃកម្ពុជា បានលើកឡើងថា ប្រព័ន្ធធនាគារបានលោតឡើងវិញក្នុងអំឡុងត្រីមាសទីមួយនៃឆ្នាំ ២០២៣ ខណៈដែលវិស័យមិនមែនធនាគារបានរីកចម្រើនបន្តិចម្តងៗ ទោះបីជាវិស័យអចលនទ្រព្យត្រូវបានរងផលប៉ះពាល់អវិជ្ជមានក៏ដោយ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានជំរុញដោយកំណើននៃការនាំចេញសម្លៀកបំពាក់ និងផលិតផលមិនមែនកាត់ដេរ ព្រមទាំងកំណើនដ៏រឹងមាំនៃសេវាកម្ម គមនាគមន៍ និងការប្រាស្រ័យទាក់ទង ព្រមទាំងការងើបឡើងវិញនៃវិស័យទេសចរណ៍។ ចាប់ពីខែមករា ដល់ខែឧសភាឆ្នាំ ២០២៣ ភ្ញៀវទេសចរអន្តរជាតិចំនួន២,១លាននាក់បានមកទស្សនាប្រទេសកម្ពុជាដែលមានចំនួនច្រើនជាងអំឡុងឆ្នាំ ២០២២ ទាំងស្រុង។ វិស័យធនាគារអាចក្លាយជាប្រភពនៃការព្រួយបារម្ភទាក់ទងនឹងការងើបឡើងវិញនៃសេដ្ឋកិច្ច ដែលបណ្តាលមកពីការកើនឡើងអនុបាតប្រាក់កម្ចីមិនដំណើរការដល់ ២,៩% ដែលកាលពីឆ្នាំមុនត្រឹមតែ២,១% ។

ពួកយើងបានប៉ាន់ប្រមាណថាទីផ្សាររថយន្តថ្មីនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៣ បានកើនឡើងក្នុងកម្រិតខ្ពស់មួយបើធៀបនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន ដោយកត់សម្គាល់ថាកាលពីឆ្នាំមុនការប្រៀបធៀបអាចត្រូវបានគេមើលឃើញថាមានកម្រិតទាប ខណៈដែលសេដ្ឋកិច្ចកំពុងងើបឡើងវិញបន្តិចម្តងៗពីផលប៉ះពាល់នៃជម្ងឺកូវីដ-១៩។

ក្នុងកំឡុងត្រីមាសទី២ ឆ្នាំ ២០២៣ RMAC បាននាំមកនូវការលក់ដ៏រឹងមាំដែលមានការកើនឡើងជាង +៥១% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នាកាលពីឆ្នាំ២០២២។ ប្រាក់ចំណេញសុទ្ធប្រចាំត្រីមាសគឺបានកើនឡើង +២៥%។

RMAC បានចេញសេចក្តីប្រកាសសំខាន់ៗមួយចំនួនជាមួយនឹងការបើកដំណើរការជាផ្លូវការក្នុងខែមេសា ឆ្នាំ ២០២៣ នៃការទទួលបានសិទ្ធិជាអ្នកផ្តល់សេវាកម្មជួសជុល និងថែទាំរថយន្ត Mercedes-Benz ដែលបានទិញយកកាលពីខែមុន។ យានដ្ឋានថែទាំរថយន្តម៉ាក Mercedes-Benz ដែលបណ្តុំដោយគ្រឿងបរិក្ខារទំនើបមានទីតាំងស្ថិតនៅមហាវិថីសម្តេច ហ៊ុន សែន។ គួរបញ្ជាក់ផងដែរថាផ្នែក Ford នៃ ក្រុមហ៊ុន RMAC បានបើកសម្ពោធយ៉ាងអស្ចារ្យនូវរថយន្តម៉ាក Ranger Raptor 2.0L Bi-Turbo (Diesel) ស៊េរីឆ្នាំ២០២៣ នៅក្នុងព្រឹត្តិការណ៍ដ៏ធំដែលរៀបចំនៅ ព្រមៀ សែនធ័រ សែនសុខ (Premier Centre Sen Sok)។ ក្នុងគោលបំណងធ្វើឱ្យការពេញចិត្តរបស់អតិថិជនកាន់តែប្រសើរឡើងបន្ថែមទៀត ក្រុមហ៊ុន RMACបានបើកដំណើរការផ្នែកទំនាក់ទំនងអតិថិជន (Call Center) ដែលបំពាក់ដោយបច្ចេកវិទ្យាចុងក្រោយបង្អស់ ដើម្បីធានាបាននូវការឆ្លើយតបរហ័សនិងប្រកបដោយប្រសិទ្ធភាពនិងតាមដានការទំនាក់ទំនងទៅនឹងតម្រូវការរបស់អតិថិជន។

ចំណែកឯ សកម្មភាពសង្គម និងមនុស្សធម៌ ថ្នាក់ដឹកនាំRMAC ពិតជាមានមោទនភាពដែលបានចូលរួមចំណែកក្នុងការជួសជុលកែលម្អអគារសិក្សាក្រពុំឈូក។ Ford Cambodia បានឧបត្ថម្ភការធ្វើដំណើរកំសាន្តរបស់អត្តពលិកក្នុងព្រឹត្តការណ៍ SeaGame ទៅកាន់ខេត្តព្រះសីហនុ ជាមួយតំណាងសំខាន់ៗនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។ RMAC បានចូលរួមយ៉ាងសកម្មនៅក្នុង TVET (ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ) ដើម្បីចែករំលែកបទពិសោធន៍ និងទាក់ទាញសិស្សានុសិស្សឱ្យចូលរួមក្នុងក្រុមរបស់យើង។

ខ្ញុំបាទតំណាងឲ្យក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណចំពោះអតិថិជនដែលមានភក្តីភាពដែលបានគាំទ្រដល់ក្រុមហ៊ុនយើងក្នុងគ្រាលំបាកក្នុងព្រះរាជាណាចក្រកម្ពុជាកន្លងមក ហើយយើងក៏សូមជូនពរឲ្យប្រជាជនកម្ពុជាទាំងអស់មានសុវត្ថិភាព និងសុខភាពល្អគ្រប់ៗគ្នា។

ក្រុមហ៊ុន
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

## មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... 3

ក្របស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ..... 5

សមាជិកក្រុមប្រឹក្សាភិបាល ..... 7

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល..... 8

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ..... 11

ក .ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ..... 11

ខ .សកម្មភាពអាជីវកម្ម..... 11

គ .ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ..... 12

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... 14

ក .លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក..... 14

ខ .រចនាសម្ព័ន្ធប្រាក់ចំណូល..... 14

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ..... 15

ផ្នែកទី៤ .ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ..... 16

ក .ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ..... 16

ខ .កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ..... 17

គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល..... 17

ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ..... 17

ង. ផលប៉ះពាល់នៃអតិផរណា..... 17

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ..... 18

ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ..... 18

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ..... 19

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (0) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (0) ២៣ ៨២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, Changan, After-Sales of Mercedes-Benz, John Deere, TCM, JCB, FUSO, Changan និង Piaggio។ ថ្មីៗនេះ RMAC បានដាក់ឱ្យដំណើរការនូវផ្នែកថ្មីមួយដែលមានឈ្មោះថា គ្រឿងបន្លាប់រថយន្ត (Automobile Acccessories) ក្នុងគោលបំណងលក់ថ្នាំលាបរថយន្តដែលមានគុណភាពខ្ពស់សម្រាប់ការងារផ្នែកជួសជុលតួរឡាន ក្រោមម៉ាក R-M (ជាផ្នែកមួយនៃក្រុមហ៊ុន BASF Group) និងអាគុយរថយន្ត ក្រោមម៉ាកយីហោគូរ៉េ RG Batteries ។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោម៖

### ការដាក់ដំណើរការផ្នែកនីមួយៗ

**ការសម្ពោធជាផ្លូវការ** Mercedes-Benz AFS

ការចាប់ផ្តើមយុទ្ធនាការរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ក្នុងនាមជាអ្នកផ្តល់សេវាសម្រាប់ម៉ាក Mercedes-Benz នៅក្នុងប្រទេសកម្ពុជា ដែលមានការអនុញ្ញាត ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣។




**ការសម្ពោធជាផ្លូវការរថយន្តម៉ាក** RANGER RAPTOR **ជំនាន់ថ្មី (ម៉ាស៊ីនប្រេងម៉ាស៊ូត)**

Ford ខេមបូឌា បានរៀបចំកម្មវិធីសម្ពោធជាផ្លូវការ រថយន្តម៉ាក Ranger Raptor 2.0L Bi-Turbo (Diesel) នៅ ដីព្រមៀ សេនធ័រ សែនសុខ ដែលមានភ្ញៀវចូលរួមជាង ៣,០០០ នាក់។




**ការសម្ពោធជាផ្លូវការ នៃផ្នែកទំនាក់ទំនងអតិថិជន** (Call Center) **នៃក្រុមហ៊ុន អ អិម អេ**

ផ្នែកទំនាក់ទំនងអតិថិជន (Call Center) ត្រូវបានបង្កើតឡើងដើម្បីបម្រើ និងពង្រឹងទំនាក់ទំនងជាមួយអតិថិជនពីគ្រប់ផ្នែក/ការផ្តល់សេវាកម្មជូនអតិថិជន។



## ព្រឹត្តិការណ៍ នៃសកម្មភាពសង្គម និងមនុស្សធម៌

### ការអប់រំ

ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) បានចូលរួមក្នុងកម្មវិធី TVET ឆ្នាំ ២០២៣ (ការអប់រំបច្ចេកទេស និងវិជ្ជាវៈ) ដែលបានដាក់តាំងបង្ហាញផ្នែកអាជីវកម្មរបស់ អ អិម អេ ជាច្រើន រួមមានរថយន្ត ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ឧស្សាហកម្ម។




### ការឧបត្ថម

Ford ខេមបូឌា បានឧបត្ថមកម្មវិធីដំណើរកំសាន្តរបស់អត្តពលិកនៅក្នុងព្រឹត្តិការណ៍ ស៊ីហ្គេម (the SEAGAME Athlete Trip) នៅខេត្តព្រះសីហនុ។ ពីធីនេះធ្វើឡើងក្រោមវត្តមាន លោកជំទាវបណ្ឌិត កុយ ពិសី រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។



## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗនៅចុងត្រីមាសទី២ នៃឆ្នាំ២០២៣ រួមមាន៖

**<u>ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖</u>**

រថយន្តម៉ាក Ford ដណ្តើមបានចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងផ្នែករថយន្ត Pick-up ក្នុងប្រទេសកម្ពុជានៅពាក់កណ្តាលត្រីមាសទី១ ឆ្នាំ២០២៣។

**<u>គ្រឿងចក្រម៉ាក John Deere៖</u>** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន រថយន្តម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**<u>លទ្ធផលហិរញ្ញវត្ថុ៖</u>**

ក្រុមហ៊ុន RMAC ទទួលបានចំណូលចំនួន ៤៨៧ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី២ នៃឆ្នាំ២០២៣ ដែលមានការកើនឡើងចំនួន +៥១% ធៀបនឹងដំណាច់ត្រីមាសទី២ នៃឆ្នាំ២០២២។ សម្រាប់ដំណាច់ត្រីមាសទី២ នៃឆ្នាំ២០២៣ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ៤៣,៦ ប៊ីលានរៀល (កើនឡើង២៥% បើប្រៀបធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២)។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ១៧,៣ ប៊ីលានរៀល ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និងឧបករណ៍ប្រតិបត្តិការបន្ថែម។

### ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ ត្រីមាសទី២ ឆ្នាំ២០២៣ និងរយៈពេលប្រៀបធៀបកាលពីឆ្នាំមុន។

| គិតជាពាន់រៀល | ត្រីមាសទី២ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី២ ឆ្នាំ២០២២ | ភាគរយ | ត្រីមាសទី២ ឆ្នាំ២០២១ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៤៧១.១០៩.៩០០ | ៩៦,៧% | ៣០៦.០២៤.១៨២ | ៩៥,១% | ៣០៧.៨៥១.៩៥៤ | ៩៧,៧% |
| **ចំណូលនៃសេវាកម្ម** | ១៥.៩៦០.៧១៥ | ៣,៣% | ១៥.៧៥៥.៥៣៦ | ៤,៩% | ៧.១៧៨.៧៩៧ | ២,៣% |
| **សរុប** | ៤៨៧.០៧០.៦១៥ | ១០០,០% | ៣២១.៧៧៩.៧១៨ | ១០០,០% | ៣១៥.០៣០.៧៥១ | ១០០,០% |

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស គិតត្រឹម

ថ្ងៃទី៣០ ខែមីថុនា ឆ្នាំ២០២៣។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៤៨៧,១ ប៊ីលានរៀល កើនឡើងចំនួន +១៦៥,៣ ប៊ីលានរៀល ឬ +៥១,៤% ភាគរយ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៣ បើធៀបនឹងត្រីមាសក្នុង ឆ្នាំ២០២២។

#### ២. ផ្នែកនៃចំណូល

ផ្នែកទាំងអស់នៃ RMAC ភាគច្រើនបានកើនឡើងពីរខ្ទង់នៅក្នុង ត្រីមាសទី២ ឆ្នាំ២០២៣ បើប្រៀបធៀបទៅនឹង ត្រីមាសទី២ នៃឆ្នាំ២០២២ ។ ផ្នែក Changan មានភាពរឹងមាំខ្លាំងក្នុងឆ្នាំ២០២៣ បើប្រៀបធៀបទៅនឹងឆ្នាំមុន ដោយសារ ផ្នែកនេះទើបតែចាប់ផ្តើមនៅឆ្នាំ ២០២២។

#### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី២ ឆ្នាំ២០២៣ | ត្រីមាសទី២ ឆ្នាំ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៤៨៧.០៧០.៦១៥ | ៣២១.៧៧៩.៧១៨ | ១៦៥.២៩០.៨៩៧ | ៥១,៤% |
| ចំណេញដុល | ៨៩.០៥៨.៩៦៧ | ៦១.៣៣៦.៦៩០ | ២៧.៧២២.២៧៧ | ៤៥,២% |
| គម្លាតចំណេញដុល | ១៨,៣% | ១៩,១% | | |
| ចំណាយ | ៣៣.១១៤.៩៨៣ | ១៧.៣២៥.៣១០ | ១៥.៧៨៩.៦៧៣ | ៩១,១% |
| ចំណាយហិរញ្ញវត្ថុ | ៦.៦៤៤.១៥៥ | ២.១០៨.៩៩៥ | ៤.៥៣៥.៦៦០ | ២១៥,១% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៤៩.២៩៩.៨២៩ | ៤១.៩០២.៨៨៥ | ៧.៣៩៦.៩៤៤ | ១៧,៧% |
| គម្លាត | ១០,១% | ១៣,០% | | |

#### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី២ ឆ្នាំ២០២៣ | ត្រីមាសទី២ ឆ្នាំ ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៤៩.២៩៩.៨២៩ | ៤១.៩០២.៨៨៥ | ៧.៣៩៦.៩៤៤ | ១៧,៧% |
| ចំណាយពន្ធ | ៥.៦៩៦.៣៦១ | ៧.១៧៩.០៧៩ | (១.៤៨២.៧១៨) | -២០,៧% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ៤៣.៦០៣.៤៦៨ | ៣៤.៧២៣.៨០៦ | ៨.៨៧៩.៦៦២ | ២៥,៦% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៩,០% | ១០,៨% | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC មានសារពើភ័ណ្ឌគ្រប់គ្រាន់ ដើម្បីបម្រើតម្រូវការក្នុងស្រុក។ RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងស្តុកទុកនូវធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី២ ឆ្នាំ២០២៣ ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០២២ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលឡើយ។

នៅខែកក្កដាឆ្នាំ២០២៣ រដ្ឋាភិបាលកំពុងរៀបចំ សម្រាប់ការផ្លាស់ដ៏សំខាន់មួយនៅក្នុងភាពជាអ្នកដឹកនាំ។ ដែលជាលទ្ធផលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរគោលនយោបាយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ១៤ សីហា ឆ្នាំ២០២៣

| | |
|---|---|
| បានឯកភាព និង អនុម័ត | បានឯកភាព និង អនុម័ត |
| ឈ្មោះ Kevin Whitcraft | ឈ្មោះ ងន សាំង |
| តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល | តួនាទី៖ នាយកប្រតិបត្តិ |

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អឹម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

